# មេរៀនទី ១១៤: យើងជាអំបិល និងជាពន្លឺ

## ម៉ាថាយ ៥:១៣-១៦

**គោលបំណង៖** យើងអាចជួយអ្នកផ្សេងទៀតឲ្យទទួលជឿព្រះ។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៥:១៣** *"អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយនោះ តើនឹងយកអ្វីដើម្បីធ្វើឲ្យប្រៃឡើងវិញបាន ជារបស់គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

មិត្តភាពរបស់អ្នកជាមួយព្រះយេស៊ូវផ្តល់ឱ្យអ្នកនូវសមត្ថភាពពិសេសមួយ ដើម្បីមានឥទ្ធិពលលើមនុស្សជុំវិញអ្នក។ អ្នកមានសមត្ថភាពក្នុងការបន្ថែមរសជាតិ និងបញ្ចេញពន្លឺដល់មិត្តរបស់អ្នកសម្រាប់ព្រះយេស៊ូវ។ សូមអាន **ម៉ាថាយ ៥:១៣-១៦** ឡើងវិញ។ តើជីវិតរបស់អ្នកដូចជាអំបិលយ៉ាងណា? តើពន្លឺ អ្វីខ្លះដែលអ្នកបានបំភ្លឺក្នុងទំនាក់ទំនងរបស់អ្នកនាពេលថ្មីៗនេះ? អង្គុយស្ងៀមស្ងាត់នៅចំពោះព្រះ។ ទូលសូមឱ្យទ្រង់ផ្តល់ឈ្មោះមនុស្សពីរនាក់ឲ្យអ្នកដែលអ្នកអាចចាប់ផ្ដើមធ្វើជាអំបិល និងពន្លឺដល់ពួកគេ ឥឡូវនេះធ្វើផែនការមួយដើម្បីចាប់ផ្តើមបង្កើត «អំបិល និងពន្លឺ »ទៅក្នុងមិត្តភាពនោះ។

**ចំរៀង៖** ១. គឺជាការល្អ ២.ព្រះបន្ទូលជាចង្កៀង ៣. ខ្ញុំដើរតាមព្រះយេស៊ូវ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ពន្លឺ និងអំបិល»**

**សម្ភារៈដែលត្រូវការ៖** កៅអី២ ក្រដាស២សន្លឹក ដែលមួយសរសេរពាក្យថា "អំបិល" និង "ពន្លឺ"

១. បិតក្រដាសដែលមានពាក្យថា "ពន្លឺ" នៅលើកៅអីមួយ និងពាក្យថា "អំបិល" នៅលើកៅអីមួយទៀតរួចដាក់នៅចុងម្ខាងនៃថ្នាក់រៀន។




២. ឲ្យកុមារទាំងអស់ឈរជាជួរបែរមុខទៅរកកៅអីនោះ។

៣. នៅពេលដែលគ្រូនិយាយថា "អំបិល" កុមារទាំងអស់ត្រូវលោតទៅខាងកៅអី ដែលបិតពាក្យថា "អំបិល"។ នៅពេលដែលគ្រូ និយាយថា "ពន្លឺ" កុមារទាំងអស់នោះត្រូវលោតទៅខាងកៅអី ដែលមានបិតពាក្យថា "ពន្លឺ" នោះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមបន្យល់កុមារថា ព្រះចង់ឲ្យយើងធ្វើជាអំបិល និងពន្លឺសម្រាប់លោកីយ៍នេះ។

## ៤. ការណែនាំមេរៀន

តើអំបិលមានរសជាតិដូចម្តេចប្អូនៗ? វាគឺប្រៃណាស់មែនទេ? ប៉ុន្តែទោះបីជាអ្នកមិនដឹងក៏ដោយថា ស្ទើរតែគ្រប់អាហារដែលយើងញ៉ាំមានអំបិលនៅក្នុងនោះ។ អំបិលមានសារៈសំខាន់ណាស់សម្រាប់យើង ដោយខ្វះមិនបាន ។ បើសិនជាឲរីពថ្ងៃដាច់ភ្លើងរហូត តើប្អូនៗនឹងមានអារម្មណ៍យ៉ាងណា? ពន្លឺក៏សំខាន់សម្រាប់យើងដែរ។ ថ្ងៃនេះព្រះយេស៊ូវមានបន្ទូលប្រាប់យើងឲ្យធ្វើជាអំបិល និងពន្លឺ។ តើវាមានន័យដូចម្តេច? តោះស្វែងយល់ពីវាថ្ងៃនេះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ខគម្ពីរថ្ងៃនេះគឺ **ម៉ាថាយ ៥:១៣** ចែងថាៈ "អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយនោះ តើនឹងយកអ្វីដើម្បីធ្វើឲ្យប្រៃឡើងវិញបាន ជារបស់គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ។"

ព្រះយេស៊ូវមានព្រះបន្ទូលថា យើងជាអំបិលនៃផែនដី។ នោះមានន័យថាយើងមានតួនាទីសំខាន់នៅក្នុងលោកីយ៍នេះ។ អំបិលមានសារៈសំខាន់ណាស់សម្រាប់ជីវិតរបស់យើង។ អំបិលធ្វើឱ្យអាហាររបស់យើងមានរសជាតិកាន់តែប្រសើរ។ ដូចគ្នានេះដែរយើងអាចជួយមនុស្សឲ្យយល់ថាព្រះល្អ ហើយថាពួកគេត្រូវការព្រះដើម្បីឲ្យពួកគេបានសង្គ្រោះ។ អំបិលក៏ការពារអាហារមិនឲ្យខូចដែរ។ ដូច្នេះហើយទើបយើងប្រឡាក់ត្រី ហើយហាលវាឱ្យស្ងួត ដើម្បីឱ្យយើងរក្សាទុកវាបានយូរ។ លោកីយនេះមានអ្វីៗជាច្រើនដែលបានខូច ប៉ុន្តែយើងអាចធ្វើជាអំបិលសំរាប់លោកីយ៍នេះ ហើយបង្ហាញមនុស្សថាយើងមានជីវិតនៅក្នុងព្រះយេស៊ូវ។ អំបិលក៏អាចរំលាយទឹកកកបានដែរ។ យើងអាចជួយរំសាយចិត្តរឹងរូសរបស់មនុស្សជាច្រើន តាមរយៈការស្រឡាញ់ពួកគេដើម្បីឱ្យពួកគេមកស្រឡាញ់ព្រះយេស៊ូវ។

ព្រះគម្ពីរក៏បានចែងថាយើងជាពន្លឺនៃលោកីយ៍នេះ។ មនុស្សដែលមិនស្គាល់ព្រះយេស៊ូវកំពុងរស់នៅក្នុងភាពងងឹត ។ ព្រះយេស៊ូវគឺជាពន្លឺនៃលោកីយ៍នេះ។ ដោយសារព្រះយេស៊ូវគង់នៅក្នុងយើង យើងត្រូវបង្ហាញពន្លឺទ្រង់ដល់មនុស្សឯទៀតនៅក្នុងពិភពលោកនេះតាមរយៈការដែលយើងធ្វើ។ យើងអាចបំភ្លឺពន្លឺនៃព្រះយេស៊ូវដោយសេចក្តីស្រឡាញ់ និងចិត្តសប្បុរស នៅពេលយើងចែកចាយដំណឹងល្អនៃព្រះយេស៊ូវ ដែលបានយាងមកដើម្បីសង្គ្រោះយើង ។

ក្នុងនាមជាអំបិល និងពន្លឺនៃលោកកិយនេះ អ្វីដែលយើងធ្វើជារៀងរាល់ថ្ងៃប៉ះពាល់ដល់លោកកីយ៍ទាំងមូល។ មនុស្សមើលមកយើងដើម្បីធ្វើជាគំរូនៃអត្ថន័យនៃការធ្វើជាកូនរបស់ព្រះ។ ពេលយើងធ្វើការជ្រើសរើសដោយល្អ ពេលយើងស្រឡាញ់អ្នកដទៃ ហើយពេលយើងស្វែងរកការលើកតម្កើងព្រះ នោះអ្នកដទៃនឹងឃើញទង្វើរបស់យើងហើយសរសើរព្រះ។ នោះហើយជារបៀបដែលយើងអាចក្លាយជាអំបិល និងជាពន្លឺនៃលោកីយ៍នេះ!

**៦. សំនួរពិភាក្សា**

១. តើព្រះយេស៊ូវមានបន្ទូលថាយើងជាអ្វីសម្រាប់ពិភពលោកនេះ? *អំបិលនិងពន្លឺ*

២. តើមានរឿងអ្វីខ្លះ ដែលយើងអាចធ្វើក្នុងនាមជាអំបិល និងពន្លឺនៃលោកិយនេះ? *ចែកចាយដំណឹងល្អអំពីព្រះយេស៊ូវ ស្រឡាញ់អ្នកដទៃ ធ្វើការជ្រើសរើសដោយល្អ នាំសិរីល្អដល់ព្រះ និងមានច្រើនទៀត*

៣. តើអ្នកអាចធ្វើអ្វីនៅថ្ងៃនេះក្នុងនាមជាអំបិល និងពន្លឺនៃលោកិយនេះ? *ឱ្យកុមារឆ្លើយ*

**៧. ល្បែងកំសាន្ត «យប់ និងថ្ងៃ»**




១. ឲ្យកុមារទាំងអស់ក្រោកឈរឡើង ហើយរងចាំការណែនាំពីគ្រូ

២. នៅពេលដែលគ្រូនិយាយថា "យប់" កុមារទាំងអស់មិនអាចផ្លាស់ទីបានទេ។ ប៉ុន្តែនៅពេលដែលគ្រូនិយាយថា "ថ្ងៃ" កុមារទាំងអស់អាចផ្លាស់ទីបាន។

៣. គ្រូត្រូវនិយាយពាក្យ"យប់" និង"ថ្ងៃ" ឲ្យកាន់តែញាប់ ដើម្បីឲ្យកុមារមានការភ័ន្តច្រឡំ។ ហើយនៅពេលដែលកុមារណាមិនអាចធ្វើបានតាមការណែនាំ កុមារនោះនឹងចាញ់ល្បែងនេះ។

៤. ប្រើពេល៣នាទីក្នុងការលេងល្បែងនេះ។

៥.បន្ទាប់ពីលេងល្បែងនេះចប់សូមសួរកុមារថា រវាងការដើរនៅពេលយប់និងដើរនៅពេលថ្ងៃមួយណាងាយស្រួលជាង។ សូមពន្យល់កុមារថា ការដើរជាមួយព្រះគឺងាយស្រួលជាង ពីព្រោះយេស៊ូវគឺជាពន្លឺនៃលោកីយ៍នេះ។ ហើយពួកយើងគួរតែធ្វើជាពន្លឺនៃលោកីយ៍នេះសម្រាប់ព្រះយេស៊ូវផងដែរ!

**៨. ខគម្ពីរចងចាំ ម៉ាថាយ ៥:១៣**

**៩. ហត្ថកម្ម ទៀន - «ខ្ញុំជាអំបិល និងពន្លឺ»**

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម ឈើចាក់ធ្មេញ កាវបិត



១. ឱ្យកុមារផាត់ពណ៌លើប្រអប់ និង ភ្លើងទៀន។

២. កាត់ប្រអប់ និង អណ្តាតភ្លើងទៀន។

៣. មូលប្រអប់នោះឲ្យក្លាយទៅជាបំពង់មួយ ហើយយកកាវបិតខាងចុងដើម្បីឱ្យវាអាច ឈរដូចជាទៀន។

៤. យកកាវបិត ឈើចាក់ធ្មេញឲ្យជាប់ជាមួយនឹងអណ្តាតភ្លើង។

៥. យកកាវបិតឈើចាក់ធ្មេញដែលមានអណ្តាតភ្លើងជាប់ជាមួយនឹងដើមទៀន។

៦. ឲ្យកុមារទាំងអស់និយាយថា "ខ្ញុំជាអំបិល និងជាពន្លឺរបស់ព្រះ!"

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ*

ខ្ញុំជាអំបិល និង ជាពន្លឺរបស់ព្រះ!

មូលវាហើយយកការបិត





ខ្ញុំជាអំបិល និង ជាពន្លឺរបស់ព្រះ!

មូលវាហើយយកការបិត



